ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៤០.កយ.ណកស/២២

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមការងារចំពោះកិច្ចទទួលបន្ទុកពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ជីវ សុខហាក់** | រដ្ឋលេខាធិការ | សហប្រធាន |
| ២-ឯកឧត្តម | **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | សហប្រធាន |
| ៣-លោកជំទាវ | **ខៀវ សុផានី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **ណាក់ សេរីវីន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥-ឯកឧត្តម | **ទឹម ស៊ីផា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| | | | |
|---|---|---|---|
| ៦-ឯកឧត្តម | **ម៉ែន ពេជ្រសាលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៧-ឯកឧត្តម | **យ៉ម ផារ៉ូត** | នាយករងខុទ្ទកាល័យ | សមាជិក |
| ៨-ឯកឧត្តម | **ឡាយ លាងសេង** | នាយករងខុទ្ទកាល័យ | សមាជិក |
| ៩-លោកស្រី | **សុន សុខាលីដា** | ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស | សមាជិក |
| ១០-លោក | **នុប សុធនវិសុទ្ធ** | ប្រធាននាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ | សមាជិក |
| ១១-លោក | **ម៉េង គួង** | ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងយុត្តិធម៌អនីតិជន | សមាជិក |
| ១២-លោក | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ និងស្ថិតិព្រហ្មទណ្ឌ | សមាជិក |
| ១៣-កញ្ញា | **សែម សេងវេថៃ** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ និងស្ថិតិរដ្ឋប្បវេណី | សមាជិក |
| ១៤-លោក | **លី សុផាណារ៉ា** | ព្រះរាជអាជ្ញានៃក្រសួងយុត្តិធម៌ | សមាជិក |
| ១៥-លោកស្រី | **សុខ វិសាល** | ព្រះរាជអាជ្ញានៃក្រសួងយុត្តិធម៌ | សមាជិក |
| ១៦-លោកជំទាវ | **គា ម៉ីម៉ី** | អនុប្រធាននាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន | សមាជិក |
| ១៧-លោក | **ខាត់ ឆវ័ន្ត** | សមាជិកខុទ្ទកាល័យ | សមាជិក |
| ១៨-លោក | **អៀម សំណាង** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | សមាជិក |
| ១៩-លោក | **ម៉ន ពីទូ** | ជំនួយការឯកឧត្តម **ជីវ សុងហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | លេខាធិការ។ |

**ប្រការ២.-**

ក្រុមការងារចំពោះកិច្ចនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ដើម្បីលើកយោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- ពិនិត្យ និងលើកយោបល់អំពីសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- ពិនិត្យ និងលើកយោបល់អំពីសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ជាមួយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣ ..**

អនុប្រធាន និងសមាជិកនៃក្រុមការងារ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់សហប្រធាន។ ក្នុងករណីសហប្រធានមួយរូបអវត្តមាន ឬមានធុរៈ សហប្រធានមួយរូបទៀត អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន។

**ប្រការ៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ១៨ ៥រោច ខែស្រាពណ៍ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហាឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ